**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋាន សញ្ញាស័ក្តិ និងសញ្ញាសម្គាល់ របស់សមាជិក សមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតឯកសណ្ឋាន សញ្ញាស័ក្តិ និងសញ្ញាសម្គាល់សម្រាប់សមាជិក សមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ។



www.pheakdeylaw.com

**មាត្រា ២.-**

ឯកសណ្ឋានរួមមាន ឯកសណ្ឋានផ្លូវការ និងឯកសណ្ឋានប្រពៃណីជាតិ ។

សញ្ញាស័ក្តិរួមមាន ស័ក្តិចុងកអាវ ស័ក្តិស្មា ស័ក្តិចុងដៃអាវទាំងសងខាង និងសញ្ញាសម្គាល់ក្រុមប្រឹក្សារាជធានី ខេត្ត ។

ឯកសណ្ឋាន និងសញ្ញាស័ក្តិនេះ ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

**មាត្រា ៣.-**

សញ្ញាសម្គាល់ជាផ្លូវការរបស់ក្រុមប្រឹក្សារាជធានី ខេត្ត គឺមានរូបសញ្ញាសាលារាជធានី ខេត្ត ដោយមានផ្ទៃខាងក្រោយពណ៌ទឹកសមុទ្រ ព័ទ្ធជារង្វង់ដោយក្បូរស្រូវពណ៌មាស ភ្ជាប់ដោយខ្សែបូ អមដោយក្បាច់ភ្ញីល្ពើពណ៌មាស ។

សញ្ញាសម្គាល់ជាផ្លូវការរបស់ក្រុមប្រឹក្សារាជធានី ខេត្ត មានគំរូដូចក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២
## អំពីសញ្ញាស័ក្តិ

**មាត្រា ៤.-**

សញ្ញាស័ក្តិនៃសមាជិក សមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ដូចតទៅ ៖

**១- សញ្ញាស័ក្តិចុងកអាវ**

សញ្ញាស័ក្តិចុងកអាវ មានផ្ទៃកម្ចីពណ៌ខៀវ រចនាតុបតែងដោយក្បាច់ក្បូរស្រូវពណ៌មាស និងក្បាច់សន្លឹកភ្ញីទេសពណ៌មាស ហើយមានរូបសញ្ញាសាលារាជធានី ខេត្ត នៅពីខាងមុខ ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាស ព័ទ្ធជុំវិញក្នុងឋាន នៅជាយផ្នែកខាងលើមានបីខ្សែ ផ្នែកខាងឆ្វេងមានបីខ្សែ ផ្នែកខាងស្តាំ និងផ្នែកខាងក្រោមមានបីខ្សែ ។

ខ្នាតសញ្ញាស័ក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោម ៖

-មានរាងជាប្រលេឡូក្រាម

-បណ្តោយ ប្រវែង០៨.០០សង់ទីម៉ែត្រ

-ទទឹង ប្រវែង០៣.៥០សង់ទីម៉ែត្រ ។

**២- សញ្ញាស័ក្តិស្មា**

សញ្ញាស័ក្តិស្មា មានផ្ទៃកម្ចីពណ៌ខៀវ រចនាតុបតែងដោយក្បាច់ក្បូរស្រូវពណ៌មាស និងក្បាច់សន្លឹកភ្ញីទេសពណ៌មាស ដាក់ខ្វែងគ្នា ហើយនៅលើក្បាច់ទាំងបីនេះមានរូបសញ្ញាសាលារាជធានី ខេត្ត មានឡេវរូបព្រះសង្ហារពណ៌មាសមួយ ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញក្នុងឋាន ។

ខ្នាតសញ្ញាស័ក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោម ៖

-បាតក្រោម ប្រវែង០៦.០០សង់ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើ ប្រវែង០៤.៥០សង់ទីម៉ែត្រ មានរាងកោងជាមុំទាល

-បណ្តោយពីលើដល់បាតក្រោម ប្រវែង១៣.០០សង់ទីម៉ែត្រ ។

**៣- សញ្ញាស័ក្តិចុងដៃអាវទាំងសងខាង**

សញ្ញាស័ក្តិចុងដៃអាវទាំងសងខាង មានផ្ទៃកម្ចីពណ៌ខៀវ រចនាតុបតែងដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ។ បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាស នៅជាយផ្នែកខាងលើមានបីខ្សែ ផ្នែកខាងឆ្វេង ផ្នែកខាងស្តាំ និងផ្នែកខាងក្រោម មានមួយខ្សែ ។



www.pheakdeylaw.com

ខ្នាតសញ្ញាស័ក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោម ៖

-មានរាងបួនជ្រុងទ្រវែង

-បណ្តោយ ប្រវែង ៣២.០០សង់ទីម៉ែត្រ

-ទទឹង ប្រវែង០៨.០០សង់ទីម៉ែត្រ ។

សញ្ញាស័ក្តិចុងកអាវ ស័ក្តិស្មា និងស័ក្តិចុងដៃអាវទាំងសងខាង មានគំរូដូចក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## អំពីឯកសណ្ឋាន និងការប្រើប្រាស់

**មាត្រា ៥.-**

ឯកសណ្ឋានសម្រាប់សម្គាល់សមាជិក សមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម ៖

**១- ឯកសណ្ឋានផ្លូវការ**

***ក- ចំពោះបុរស***

- អាវដៃវែងកុជពណ៌ស កក្រង់ កាត់រាងអាវធំ គ្មានឆែកខ្នង ដាក់ឡេវរូបព្រះសង្ហារចំនួនប្រាំពីរ ដែលឡេវនីមួយៗ មានអង្កត់ផ្ចិតប្រវែង០២.៥០សង់ទីម៉ែត្រ ។ ចុងកអាវទាំងសងខាងមានស័ក្តិចុងកអាវ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិមួយគូ ។ ដៃអាវវែងត្រឹមភ្នែកគោលដៃ ហើយនៅចុងដៃអាវ មានស័ក្តិចុងដៃអាវ ។ មានហោប៉ៅចំនួនបួន ហោប៉ៅពីរខាងលើដេរប៉ះបត់ផ្នត់កណ្តាល ហោប៉ៅពីរខាងក្រោមចោះបង្កប់ ដែលមានគម្របរាងស្លឹកពោធិ៍ស្រួចចំកណ្តាល ចោះរន្ធឡេវសម្រាប់បិទ ហើយនៅលើគម្របហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិតប្រវែង ០១.៨០សង់ទីម៉ែត្រ ។

- ខោជើងវែងពណ៌ស គចង្កេះ ក្លិបកក្រោយខាងឆ្វេងពីរ ខាងស្តាំពីរ ហោប៉ៅចំហៀងនៅសងខាង ហោប៉ៅចោះក្រោយមួយនៅខាងស្តាំ ប្រើសាច់ក្រណាត់ដូចគ្នាទៅនឹងក្រណាត់អាវ ។

- ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

***ខ- ចំពោះនារី***

- អាវដៃវែងជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំង គ្មានឆែកខ្នង បិទឡេវមុខ មានដាក់ឡេវរូបព្រះសង្ហារចំនួនប្រាំ ដែលឡេវនីមួយៗមានអង្កត់ផ្ចិតប្រវែង០២.៥០សង់ទីម៉ែត្រ ។ ចុងកអាវទាំងសងខាង មានស័ក្តិចុងកអាវ មានបន្ទះស័ក្តិលើស្មា សម្រាប់ដាក់ស័ក្តិមួយគូ គ្មានហោប៉ៅ ។ ដៃអាវវែងត្រឹមភ្នែកគោល ចុងដៃអាវ មានស័ក្តិចុងដៃអាវ។

- ប្រើសំពត់សំឡូយអំពីហូល ពណ៌ខៀវចាស់ មានសម្រុងលើភ្នែកគោលនៃស្មងជើង ប្រវែងពី១០ ទៅ ១៥សង់ទីម៉ែត្រ អាស្រ័យទៅតាមមាឌ និងកម្ពស់ ។

- ស្បែកជើងអេស្កាប៉ាងឃ្លុបមុខ ឃ្លុបក្រោយ គ្មានចងខ្សែ មានកែងពណ៌ខ្មៅ ។

ឯកសណ្ឋានផ្លូវការសម្រាប់បុរស និងនារី មានគំរូដូចនៅក្នុងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ។

**២- ឯកសណ្ឋានប្រពៃណីជាតិ**

***ក- ចំពោះបុរស***

- អាវដៃវែងកុជពណ៌ស កក្រង់ កាត់រាងអាវធំ គ្មានឆែកខ្នង ដាក់ឡេវរូបព្រះសង្ហារចំនួនប្រាំពីរ ដែលឡេវនីមួយៗ មានអង្កត់ផ្ចិតប្រវែង០២.៥០សង់ទីម៉ែត្រ ។ ចុងកអាវទាំងសងខាងមានស័ក្តិចុងកអាវ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិមួយគូ ។ ដៃអាវវែងត្រឹមភ្នែកគោលដៃ ហើយនៅចុងដៃអាវ មានស័ក្តិចុងដៃអាវ។ មានហោប៉ៅចំនួនបួន ហោប៉ៅពីរខាងលើ និងហោប៉ៅពីរខាងក្រោមចោះបង្កប់ ដែលមានគម្របរាងស្លឹកពោធិ៍ស្រួចចំកណ្តាល ចោះរន្ធឡេវសម្រាប់បិទ ហើយនៅលើគម្របហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិតប្រវែង ០១.៨០សង់ទីម៉ែត្រ ។



www.pheakdeylaw.com

- ប្រើសំពត់ផាមួងចងក្បិន ពណ៌ខៀវចាស់
- ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ដល់ក្បាលជង្គង់ ។

*ខ- ចំពោះនារី*

- អាវធំបរាង ក្រណាត់ប៉ាក់ពណ៌សដៃវែងត្រឹមភ្នែកគោលដៃ កវៀលមូល ខាងមុខធ្លាក់ចុះពីក្បាលឆ្អឹងដងកាំបិតប្រវែង០១.៥០សង់ទីម៉ែត្រ និងត្រង់ស្មាឃ្លាតពីគល់ក ប្រមាណ០២.៥០សង់ទីម៉ែត្រ ឬ០៣.០០សង់ទីម៉ែត្រ អាស្រ័យទៅតាមមាឌរបស់នារី ។ អាវនេះគ្មានស័ក្តិស្មា និងស័ក្តិចុងកអាវទេ ប៉ុន្តែមានស័ក្តិចុងដៃអាវទាំងសងខាង។
- ពានាក្រមាពណ៌តាមសំពត់ សាច់ក្រមាដែលធ្វើពីសូត្រ មានផ្ទៃពណ៌ខ្ចីជាងសំពត់
- ប្រើសំពត់ផាមួងចងក្បិន ពណ៌ខៀវចាស់
- ស្បែកជើងអេស្កាប៉ាងឃ្លុបមុខ ឃ្លុបក្រោយ គ្មានចងខ្សែ មានកែងពណ៌ខ្មៅ ។

ឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និងនារី មានគំរូដូចនៅក្នុងឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦ .-**

ឯកសណ្ឋាន និងសញ្ញាស័ក្តិសម្រាប់សមាជិក សមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបានអនុញ្ញាតឲ្យសាមីជនប្រើប្រាស់តែក្នុងអាណត្តិប៉ុណ្ណោះ ។

**មាត្រា ៧ .-**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់សមាជិក សមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបានកំណត់ដូចខាងក្រោម៖

- ឯកសណ្ឋានផ្លូវការ ប្រើសម្រាប់ក្នុងឱកាសទទួលគ្រឿងឥស្សរិយយស ទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗរបស់រដ្ឋ ឬតាមការកំណត់របស់ថ្នាក់ដឹកនាំស្ថាប័ន ។
- ឯកសណ្ឋានប្រពៃណីជាតិ ប្រើសម្រាប់ក្នុងទិវាបុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ឬក្នុងវត្តអារាម ឬទីកន្លែងផ្សេងៗ ។

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះ ត្រូវស្លៀកពាក់ទៅតាមការកំណត់ក្នុងសេចក្តីអញ្ជើញជាផ្លូវការរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ ឬក្រសួងព្រះបរមរាជវាំង ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ៨ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com

## ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ១៣៦៤ អនក្រ.បក ថ្ងៃទី.១៨.ខែ.សីហា...ឆ្នាំ២០១៦
ស្តីពីសញ្ញាសម្គាល់សមាជិក សមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត

### សញ្ញាសម្គាល់



## ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៦

ស្តីពីសញ្ញាស័ក្តិសម្រាប់សមាជិក សមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត

ស័ក្តិចុងកអាវ



ស័ក្តិស្មា



ស័ក្តិចុងដៃអាវ



www.pheakdeylaw.com

## ឧបសម្ព័ន្ធទី៣

នៃអនុក្រឹត្យលេខ..១៣៦..អនក្រ.បក ថ្ងៃទី..២៩..ខែ..កក្កដា..ឆ្នាំ២០១៦
ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋានសម្រាប់សមាជិក សមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត

## ឯកសណ្ឋានផ្លូវការ



ឧបសម្ព័ន្ធទី៤

នៃអនុក្រឹត្យលេខ .................... ថ្ងៃទី........ខែ............ឆ្នាំ២០១

ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋានសម្រាប់សមាជិក សមាជិកាក្រុមប្រឹក្សារាជធានី ខេត្ត

## ឯកសណ្ឋានប្រពៃណី



www.pheakdeylaw.com